# City of Seattle

Gregory J. Nickels, ចៅហ្វាយក្រុង

**Seattle Public Utilities**

Chuck Clarke, នាយក

ថ្ងៃទី 29 ខែធ្នូ ឆ្នាំ 2008

សូមជំរាបមកដល់ម្ចាស់ហាងពាណិជ្ជកម្មទាំងអស់:

ផ្នែកទឹកភ្លើងសាធារណៈក្រុង Seattle (SPU) បានចេញសេចក្តីព្រាងបទបញ្ញត្តិប្រតិបត្តិសំរាប់ឲ្យសាធារណៈជនបញ្ចេញយោបល់ ដែលប្រហែលប៉ះពាល់ ដល់អ្នក **បើអ្នកមានទូរដាក់សំរាមឬធុងដាក់សំរាមឬធុងសំរាប់សំណល់ផលិតឡើងវិញ ដែលពេលបច្ចុប្បន្នបានដាក់នៅតាមច្រកផ្លូវសាធារណៈ ឬនៅលើ ចិញ្ចើមថ្នល់ Downtown, Belltown ឬនៅតំបន់ Pioneer Square។** សេចក្តីព្រាងបទបញ្ញត្តិមានទាក់ទងទៅនឹងសំរាម, សំណល់ផលិតឡើងវិញ, ធុងស្មៅនិងធុងសំណល់អាហារ ហើយនិងស្បោងដាក់នៅលើចិញ្ចើមឬនៅតាមច្រកផ្លូវសាធារណៈទូរទាំងទីក្រុង; ទោះបីយ៉ាងណាក៏ដោយ គឺវាមានន័យសំខាន់ជាពិសេសសំរាប់ Downtown, Belltown និងតំបន់ Pioneer Square ក្នុងឆ្នាំ 2009។ កន្លែងទាំងអស់នេះគឺជាមណ្ឌលចាត់តាំងពាណិជ្ជកម្ម សំរាប់កម្មវិធី "ច្រកផ្លូវស្រឡះ" ដោយចាប់ផ្តើមពីថ្ងៃទី **30 ខែមិនា ឆ្នាំ 2009** ដែលរៀបចំជាកន្លែងហាមឃាត់ ថានៅមុនពេលនិងក្រោយពេលប្រមូលសំរាម ធុងអាចទុកចោលនៅតាមច្រកផ្លូវសាធារណៈបានយូរប៉ុន្មាន ហើយនិងផ្តល់ឲ្យមានសេវាប្រមូលស្បោងដែលបង់ឈ្នួលមុនជាការជំនួសវិញ។

សេចក្តីសង្ខេបយ៉ាងខ្លីនៃសេចក្តីព្រាងបទបញ្ញត្តិគឺចុះនៅខាងខ្នងនៃលិខិតនេះ។ ថែមពីលើនោះ ក្រដាសចម្លងនៃសេចក្តីព្រាងបទបញ្ញត្តិប្រតិបត្តិនេះនិង ការបញ្ចូលគ្នានៃផែនទីមណ្ឌលចាត់តាំងពាណិជ្ជកម្ម Downtown, Belltown និង Pioneer Square គឺដាក់បញ្ចូលនៅក្នុងសំបុត្រនេះ។ បើអ្នកចង់ធ្វើយោបល់របស់អ្នកអំពីសេចក្តីព្រាងបទបញ្ញត្តិឬមានសំណួរនានាអំពីកម្មវិធី "ច្រកផ្លូវស្រឡះ" សូមអ៊ីមែលទៅ SPUClearAlleys@Seattle.Gov ឲ្យបានត្រឹមថ្ងៃទី **21 ខែមករា ឆ្នាំ 2009។**

អ្នកក៏អាចទាក់ទងទៅ Gabriella Uhlar-Heffner តាមលេខ (206) 386-9772 បើអ្នកមានយោបល់នានានៅលើសំណើសេចក្តីព្រាងបទបញ្ញត្តិ ឬមានសំណួរនានាអំពីកម្មវិធី ច្រកផ្លូវស្រឡះ" ដែលនឹងមាន។ ឯកសារនៃ "សំណួរដែលបានសួរញឹកញាប់" ដែលទាក់ទងនឹងកម្មវិធី "ច្រកផ្លូវស្រឡះ" ដែលនឹងមានក៏គឺមានឃើញនៅក្នុងសំបុត្រនេះដែរ។ គ្រប់ ឯកសារទាំងនេះ ពេលឆាប់ៗនឹងអាចមាននៅក្នុងការបកប្រែជាភាសាផ្សេងៗនៅក្នុងទំព័រវ៉ិបសៃថ៍របស់ SPU ដែលបានយកចិត្តទុកដាក់ចំពោះកម្មវិធីនេះ។

សូមអរគុណចំពោះអ្នក សំរាប់ការផ្តល់យោបល់នានាចំពោះសេចក្តីព្រាងបទបញ្ញត្តិប្រតិបត្តិនៅក្នុងឱកាសពេលបុណ្យដ៏មមារញឹកនេះ។

ដោយក្តីស្មោះស្រ័គ្រ

Timothy Croll
នាយកផ្នែកសំរាមមិនកែប្រែ
ផ្នែកទឹកភ្លើងសាធារណៈ

Seattle Municipal Tower, 700 5th Ave, Suite 4900, PO Box 34018, Seattle, WA 98124-4018
Tel: (206) 684-3000, TTY/TDD: (206) 233-7241, Fax: (206) 684-4631, Internet Address: http://www.seattle.gov/util/
សកម្មភាពរបស់នយោជកនៃភាពមិនរើសអើង ក្នុងឱកាសមានការងារធ្វើស្មើៗគ្នា។
ការសម្របទៅតាមស្ថានការណ៍សំរាប់ប្រជាជនដែលមានភាពពិការ ដែលផ្តល់ការបំរើតាមការស្នើសុំ។